

# ជំពូកទី៩

# ការរៀនប្រើភាសានិយាយ

កុមារដែលអាចស្តាប់ឮភាពខុសគ្នារវាងពាក្យជាច្រើន ឬកុមារបានក្លាយជាថ្លង់ក្រោយពេលចេះនិយាយហើយ អាចមានលទ្ធភាពចេះប្រើភាសានិយាយបាន។ កុមារថ្លង់ស្ទើរតែទាំងអស់និយាយសម្លេងខុសពីកុមារស្តាប់ឮធម្មតា។ ជាញឹកញាប់មនុស្សដែលមិនធ្លាប់ស្គាល់កុមារថ្លង់ណាម្នាក់ ពិតជាមានការពិបាកយល់សម្តីរបស់គេណាស់។ បើសិនជាអ្នកប្រើប្រាស់ភាសានិយាយជាមួយកូន នោះកូនរបស់អ្នកត្រូវការឱ្យជួយជ្រោមជ្រែងបន្ថែមទៀត ខណៈដែលកូនរៀនអានដោយមើលមាត់ និងនិយាយឱ្យបានច្បាស់ល្អ។ អ្នកនឹងបានលទ្ធផលល្អ បើសិនជាអ្នកនិងកូនរីករាយរៀនពាក្យ និងភាសារួមគ្នា។ ត្រូវចាំថាមនុស្សគ្រប់គ្នានៅក្នុងផ្ទះ ត្រូវតែនិយាយរកកុមារឱ្យបានច្រើនតាមដែលអាចធ្វើបាន។

ដំបូង កុមារចាប់ផ្តើមយល់ពាក្យដែលមនុស្សគ្រប់គ្នាប្រើប្រាស់។ បន្ទាប់មកកុមារប្រើប្រាស់ពាក្យសំរាប់មនុស្ស និងវត្ថុសំខាន់ៗចំពោះខ្លួន ដែលពួកគេឃើញរាល់ថ្ងៃ។ ក្រោយមកកុមារនឹងរៀនពាក្យជាច្រើនប្រភេទផ្សេងៗគ្នា។ ប្រការនេះជួយកុមារឱ្យចេះនិយាយជាប្រយោគ។ សូមអានជំពូកទី3 គោលការណ៍ណែនាំនៃការបង្រៀនភាសាដល់កូនរបស់អ្នក។

## ▶ របៀបទាក់ទាញចំណាប់អារម្មណ៍កូនរបស់អ្នក

កុមារត្រូវការឃើញចលនាបបូរមាត់របស់អ្នក ដើម្បីយល់ពាក្យដែលអ្នកបាននិយាយ។ ធ្វើយ៉ាងណាឱ្យកូនមើលអ្នកនៅពេលអ្នកនិយាយទៅរកកូន។

បើសិនជាកូនឆ្លើយតបនឹងឈ្មោះរបស់ខ្លួន ចូរប្រើវាដើម្បីទាក់ទាញការយកចិត្តទុកដាក់ពីកូន។ បើសិនជាកូនមិនឆ្លើយតប ចូរសាកល្បងគោះកំរាលឥដ្ឋ ធ្វើដូច្នេះកូនបានដឹងពីភាពខ្ទរមកវិញ។






## ▶ វិធីរក្សាចំណាប់អារម្មណ៍របស់កូន

- ចូរនិយាយអំពីអ្វីមួយដែលកូនស្គាល់ និងអាចមើលឃើញដូចជា ម្ហូបអាហារ ខោអាវ និងល្បែងលេងរបស់កូន ។
- ចូរនិយាយពីអ្វីមួយដែលកូនចាប់អារម្មណ៍ ។ បើសិនជាកូនចូលចិត្តលេងតុក្កតា ចូរនិយាយអំពីអ្វីៗដែលកូនកំពុងធ្វើ ។
- ចូរនិយាយឱ្យបានញឹកញាប់ មិនត្រឹមតែពេលបង្រៀននោះទេ ។ កុមារអាចមិនទាន់យល់ពាក្យ តែវាអាចជួយកុមារឱ្យស្គាល់ពាក្យបានច្រើនថែមទៀត ។



**ត្រូវនៅទល់មុខកូន ពេលអ្នកនិយាយ និងត្រូវមានពន្លឺល្អ ដើម្បីឱ្យកុមារឃើញមុខរបស់អ្នក ។**

- ចូរព្យាយាមកាត់បន្ថយសូរសម្លេងដែលមានជុំវិញអ្នក ។ ចូរចាំថាត្រូវនិយាយឱ្យជិតកុមារ ។ ត្រូវចាំថា បើសិនជាកុមារឮសម្លេងនៅត្រចៀកខាងណាខ្លាំងជាង អ្នកត្រូវនិយាយនៅក្បែរត្រចៀកនោះ ។

## ▶ របៀបជួយកូនរៀនអំពីការបន្លឺសម្លេង (និយាយ)

ចូរនិយាយតាមធម្មតាទៅរកកុមារស្តាប់ឮម្នាក់ គឺគ្រប់គ្រាន់ដែលអាចឱ្យក្មេងរៀននិយាយបាន ។ ប៉ុន្តែដើម្បីជួយបង្រៀនកុមារមិនអាចស្តាប់ឮល្អឱ្យចេះនិយាយ ក្មេងត្រូវការផ្ចង់ស្មារតីស្តាប់ និងត្រូវចាំសម្លេងនិយាយដែលចេញជាពាក្យផ្សេងៗគ្នាឱ្យច្បាស់ ។ ជាការបន្ថែមលើការនិយាយសម្លេងងាយៗទៅរកកុមារ អ្នកគួរឱ្យកូនផ្ចិតផ្ចង់ស្តាប់ និងប្រើសម្លេងនិយាយឱ្យជាក់លាក់ ។ គ្រប់ភាសានីមួយៗមានសម្លេងងាយ និងសម្លេងពិបាកដើម្បីឱ្យកុមាររៀន ។ ចូរបង្រៀនសម្លេងងាយៗជាមុន (ដូចជាពាក្យ បា មុនពាក្យ តា) ។

រៀងរាល់ពីរសប្តាហ៍ម្តង ចូរជ្រើសរើសសម្លេងនិយាយខុសៗគ្នា និងប្រើវាឱ្យបានញឹកញាប់ដែលអាចធ្វើបាននៅក្នុងកិច្ចសន្ទនា ប្រើតែពាក្យនោះសុទ្ធសាធ ឬក៏ប្រើពេលលេងល្បែងកំសាន្ត ។ ស្នើឱ្យមនុស្សដទៃទៀតប្រើប្រាស់សម្លេងនិយាយដូចគ្នាផងដែរ ។




**ធ្វើសម្លេងដែលបានជ្រើសរើសនោះឡើងវិញ ឱ្យញឹកញាប់ ។ ចូរប្រើតែសម្លេងនិយាយមួយមុខគត់ផងដែរ សំរាប់ជាឧទាហរណ៍ ដោយនិយាយថា :- រ-រ-រ-រងា ។**

## ▶ របៀបជួយកូនអ្នករៀនពាក្យដំបូង

កូនត្រូវតែរៀនមើលបបូរមាត់របស់អ្នក និងរៀនស្ដាប់ដោយប្រយ័ត្នបំផុត ។ ដូច្នេះជាការប្រសើរ ចូរបង្រៀនម្ដងតែពីរបីពាក្យបានហើយ ។

ចូរមើលបបូរមាត់របស់អ្នកនៅមុខកញ្ចក់ ឬមើលបបូរមាត់មនុស្សឯទៀត ពេលពួកគេនិយាយគ្នា ដើម្បីឱ្យឃើញសម្លេងប្រភេទណាមួយនៅលើបបូរមាត់អ្នក ។ ពេលខ្លះសម្លេងខុសគ្នា តែមើលឃើញដូចគ្នានៅលើបបូរមាត់ ។ ក្នុងពេលឆាប់ៗអ្នកនឹងបានឃើញថា វាពិបាករៀនអានតាមបបូរមាត់ដូចម្ដេចនោះ ។



**ពាក្យ "ជា" "ជាង" "លាង" មើលទៅដូចគ្នាទាំងអស់នៅលើបបូរមាត់ ។**

**ដើម្បីជួយកូនរៀនពាក្យមួយ :-**

1. ជ្រើសរើសពីរបីពាក្យ ដែលងាយមើលឃើញលើបបូរមាត់ ។ សម្លេងខ្លះងាយជាងសម្លេងខ្លះទៀត ។ សម្លេងដូចជា "ប " កន្លែងដែលបបូរមាត់ចាប់ផ្ដើមបិទ និងបើកមកវិញ គឺងាយមើលឃើញបំផុត ។




2. ជ្រើសរើសពាក្យដែលងាយស្ដាប់ឮ ។ សម្លេងខ្លះឮខ្លាំងជាងសម្លេងខ្លះទៀត ។ សម្លេងដែលឮខ្លាំងបំផុតដូចជា "អា" ក្នុងពាក្យ "កា" "តា" សម្លេង "អូ" ក្នុងពាក្យ "បូក" និងសម្លេង "អ៊ី" ក្នុងពាក្យ "ពីរ" ។ ពាក្យទាំងនេះ គឺជាពាក្យល្អសំរាប់ចាប់ផ្ដើមដំបូង ។

3. បើសិនជាពាក្យនោះនៅខាងដើម ឬខាងចុងល្បះ គឺវាងាយស្ដាប់ឮបំផុត ។

4. ដើម្បីបង្រៀនពាក្យ អ្នកត្រូវប្រើវាឱ្យបានរាប់រយដង ។ ដូច្នេះជ្រើសរើសពាក្យដែលអាចប្រើក្នុងការជជែកលេងឱ្យបានច្រើនដងនៅរៀងរាល់ពេលថ្ងៃ ។



5. ប្រើពាក្យដូចគ្នាសារចុះសារឡើងនៅក្នុងស្ថានភាពដូចគ្នា ។ បើសិនជាចាំបាច់ ចូរនិយាយវាឡើងវិញ ហើយកុមារតូចៗ ភាគច្រើនតែងចូលចិត្តទង្វើបែបនេះ ។

6. និយាយឱ្យច្បាស់ៗ ។ ប្រើពាក្យឱ្យប្រយ័ត្ន កុំបំផ្លើសចលនាមាត់ ។

7. កត់ត្រាពាក្យមានប្រយោជន៍ក្នុងបញ្ជីខ្លីមួយ ជាពាក្យដែលអ្នកចង់ឱ្យកូនរៀន និងស្នើឱ្យមនុស្សក្នុងផ្ទះប្រើវាឱ្យបានញឹកញាប់ ។ ជ្រើសរើសពាក្យណាដែលងាយមើលឃើញលើបបូរមាត់ ។

**មនុស្សគ្រប់គ្នាអាចប្រើពាក្យដូចគ្នា ទោះជាសំរាប់អ្វីក៏ដោយ ដែលមានឈ្មោះខុសគ្នាដូចជា "អាវរងា" ឬ "ខោ" ។**




នៅពេលអ្នកប្រាកដក្នុងចិត្តថា កូនយល់ពាក្យអ្នកបានប្រើកន្លងមកហើយ ចូរបង្រៀនពាក្យថ្មីថែមទៀតដែលមើលឃើញច្បាស់លើបបូរមាត់ និងមានសម្លេងខុសប្លែកពីពាក្យពីរបីមុនៗ ។ ចូរបន្តហាត់ពាក្យចាស់ៗ ខណៈដែលអ្នកបង្រៀនពាក្យថ្មីៗដល់កូន ។

## កុមារត្រូវការស្គាល់ប្រភេទពាក្យខុសៗគ្នា

កុមារត្រូវការរៀនប្រភេទពាក្យខុសៗគ្នាជាច្រើនទៀត បន្ថែមពីលើការរៀនឈ្មោះវត្ថុ និងមនុស្ស ។ ប្រការនេះជួយកុមាររៀនពីព្រឹត្តិការណ៍ទាំងឡាយនៅជុំវិញខ្លួន គឺត្រៀមបម្រុងកុមារឱ្យចេះនិយាយជាប្រយោគនាពេលខាងមុខ ។ ចូរអនុវត្តឱ្យប្រាកដគ្រប់ចំណុចដូចតទៅ :-

- **ឈ្មោះសមរម្យ**
  (ឈ្មោះដែលបានដាក់ឱ្យបុគ្គលម្នាក់ៗ)



- ពាក្យនៃ**សកម្មភាព**




- ពាក្យនៃ**ការពិពណ៌នា**




- ពាក្យនៃ**អារម្មណ៍**




ការស្គាល់ "ពាក្យនៃ**ឈ្មោះ**" "ពាក្យនៃ**សកម្មភាព**" "ពាក្យនៃ**ការពិពណ៌នា**" និង"ពាក្យនៃ**អារម្មណ៍**" ជួយឱ្យកុមារចេះប្រើពាក្យទាំងនោះ ដើម្បីគិតអំពីព្រឹត្តិការណ៍ទាំងឡាយនៅជុំវិញពួកគេ ។

ពេលកុមារស្គាល់ន័យរបស់ពាក្យ ពួកគេរៀនប្រៀបធៀប ចាត់ជាប្រភេទ និងរៀបចំតាមលំដាប់នៃវត្ថុ ដោះស្រាយបញ្ហា ហើយចេះរៀបរាប់អំពីអារម្មណ៍ ។ សូមអានជំពូកទី7 សំរាប់ព័ត៌មានស្ដីពីរបៀបកុមារអភិវឌ្ឍភាសា និងការគិត ។

### ▶ របៀបលើកទឹកចិត្តកូនឱ្យចាប់ផ្តើមប្រើពាក្យ

បើសិនជាកូនពិបាកស្តាប់ឮសម្លេងនិយាយ កូនអាចរៀនមើលបបូរមាត់របស់អ្នក ដែលផ្តល់តម្រុយឱ្យកុមារដឹងអំពីរបៀបនិយាយពាក្យទាំងនេះដោយខ្លួនឯង។ វាជាការសំខាន់ក្នុងការចងចាំ ទោះបីសម្លេងជាច្រើនមើលឃើញដូចគ្នាលើបបូរមាត់ក៏ដោយ។

1. លើកទឹកចិត្តកុមារឱ្យប្រើពាក្យនិយាយពេលលេងកំសាន្ត។ អង្គុយកន្លែងមានពន្លឺល្អទល់មុខកុមារ និងបង្ហាញវត្ថុដែលកុមារចាប់អារម្មណ៍ ដូចជាប្រដាប់លេងសំណប់ចិត្តរបស់គេ។ លើកទឹកចិត្តកុមារឱ្យមើលចលនាបបូរមាត់របស់អ្នកខណៈដែលអ្នកនិយាយឈ្មោះប្រដាប់លេងនោះ។ ចូរនិយាយដដែលៗឱ្យបានច្រើនដង។

2. ឱ្យកុមារថាត្រាប់តាមអ្នក។







**និយាយតាមធម្មតា និងឱ្យច្បាស់ល្អពិតប្រាកដ។ ប្រការនេះ ជួយកូនឱ្យចេះអានដោយមើលមាត់មនុស្សផ្សេងទៀតនិយាយអ្វីមួយដែលដូចគ្នា។**

3. អង្គុយជាមួយកូននៅមុខកញ្ចក់ ធ្វើដូច្នេះកូនអាចឃើញមុខរបស់កូននិងអ្នក ទាំងក្រៅនិងក្នុងកញ្ចក់។ បង្ហាញវត្ថុមួយដល់កូន។ និយាយឈ្មោះវត្ថុនោះ បន្ទាប់មកឱ្យកូនថាត្រាប់តាមអ្នក។




4. អនុវត្តជំហានទាំងនេះសារឡើងវិញជាមួយពាក្យប្លែកៗ ជាពិសេសពាក្យនៃឈ្មោះអ្វីមួយដែលកូនចាប់អារម្មណ៍ក្នុងពេលអនុវត្តនេះ។

កូនអ្នកមិនអាចនិយាយពាក្យឱ្យត្រូវចំៗភ្លាមនោះទេ។ ត្រូវចាំថា កូនមិនអាចស្តាប់ឮសម្លេងនៃពាក្យទាំងស្រុងឡើយ។ ដំបូងអ្នកអាចមិនយល់ពាក្យអ្វីៗដែលកូនបាននិយាយចេញមក តែត្រូវសរសើរកូនដែលខំព្យាយាមនិយាយ និងមិនត្រូវកង្វល់ច្រើន អំពីរឿងកូននិយាយមិនទាន់ច្បាស់ឡើយ។

### ▶ លើកទឹកចិត្តកូនឱ្យចេះប្រាស្រ័យទាក់ទងតាមតម្រូវការសាមញ្ញ

នៅពេលកូនចង់បានអ្វីមួយ កូនពិតជាមានឆន្ទៈចង់រៀនពាក្យដែលជួយបំពេញតម្រូវការរបស់ខ្លួន ។

- ពេលណាកុមារចង់បានអ្វីមួយ លើកទឹកចិត្តកុមារឱ្យនិយាយពាក្យអ្វីមួយដែលគេចង់បាននោះ ។




### ▶ របៀបលើកទឹកចិត្តកូនឱ្យឆ្លើយសំណួរខាយៗ

ការសួរសំណួរដល់កូន គឺជាវិធីដ៏ល្អក្នុងការលើកទឹកចិត្តកូនឱ្យនិយាយ ។ ចូរចងចាំថា ដើម្បីជួយកូនឱ្យដឹងថាអ្នកសួរសំណួរ អ្នកត្រូវប្រើទឹកមុខ (ដូចជាជ្រួញចិញ្ចើម និងមើលដោយក្ដីងឿងឆ្ងល់) និងប្រើចលនារាងកាយ (ដូចជាងើយក្បាលរបស់អ្នក) ។

- ដើម្បីចាប់ផ្ដើម ព្យាយាមសួរសំណួរដែលតម្រូវឱ្យមានចម្លើយ "ចាស់" "បាទ" ឬ "ទេ"។ នៅពេលកូនគ្រវីក្បាល "ចាស់" "បាទ" ឬ "ទេ" ចូររំលឹកកូនឱ្យប្រើពាក្យដែលបញ្ជូនសារដូចគ្នា ។







- សួរសំណួរដែលអាចឆ្លើយបាននឹងពាក្យទោល ។



បើសិនជាកុមារឆ្លើយ ចូរសរសើរក្មេង។ បើសិនជាកុមារមិនឆ្លើយ :-

- កុមារអាចមិនយល់ពាក្យដែលអ្នកប្រើ។
- កុមារអាចមិនយល់ថា សំណួរនោះទាមទារចម្លើយមកវិញ។

ដំបូង អ្នកអាចបង្រៀនកូនអំពីការសួរសំណួរដោយឆ្លើយជំនួសកូន។ មួយសន្ទុះក្រោយមក កូននឹងយល់គំនិតនេះ។







- បង្កើតស្ថានភាពដែលតម្រូវឱ្យកូនសួររកអ្វីមួយ។ បងស្រីរបស់ ***អាណា*** ឱ្យចានទទេមួយទៅ ***អាណា*** ហើយរង់ចាំឱ្យ ***អាណា***សួររកសណ្ដែក។




## ▶ ជួយកូនឱ្យយកចិត្តទុកដាក់លើរបៀបដែលពាក្យបន្លឺចេញមក

ពេលណាមនុស្សនិយាយ ពួកគេតែងបង្កើនសម្លេងលើពាក្យខ្លះ (ខ្លាំងបំផុត) ច្រើនជាងពាក្យខ្លះទៀត និយាយពាក្យខ្លះលឿនជាងពាក្យខ្លះទៀត (ចង្វាក់) និងប្ដូរទៅរបៀបខ្ពស់ ឬជ្រៅនៃសម្លេងនិយាយ (កំរិតសូរ-លើកដាក់សម្លេង)។ មនុស្សក៏បង្ហាញអារម្មណ៍ដោយការលើកដាក់សម្លេងនិយាយរបស់ពួកគេផងដែរ។ វិធីប្លែកៗគ្នានៃការនិយាយទាំងនេះ បានបន្ថែមគ្រប់អត្ថន័យទាំងអស់ទៅលើការបញ្ជូនសារ។




**ចូរស្ដាប់ការលើកដាក់សម្លេងរបស់ម្ដាយ *ម៉ាញូល* និងការបង្កើនសម្លេងនៃពាក្យនិយាយរបស់គាត់ "ទេ" ដើម្បីជួយឱ្យ *ម៉ាញូល*យល់ន័យរបស់គាត់។**

### ▶ របៀបជួយឱ្យកូននិយាយអ្វីៗតាមវិធីខុសៗគ្នា

ខណៈពេលកូនរៀនស្ដាប់ និងមើលវិធីខុសៗគ្នានៃអ្វីៗដែលមនុស្សនិយាយ កូនត្រូវការរៀននិយាយទៅតាមវិធីផ្សេងៗគ្នាផងដែរ ។

- ចូរលេងល្បែងណា ដែលលើកទឹកចិត្តកុមារឱ្យនិយាយសម្លេងដែលសំដែងពីអារម្មណ៍ ។






- លើកទឹកចិត្តកូនឱ្យច្រៀងចម្រៀង ។ ប្រការនេះ ជួយសម្លេងរបស់ក្មេងឱ្យឡើងខ្ពស់ទាប និងជួយផ្លាស់ប្ដូរចង្វាក់នៃសម្លេងនិយាយផងដែរ ។



## ▶ របៀបជួយកូនឱ្យធ្វើតាមសំណើសាមញ្ញ

ខណៈដែលកូនស្គាល់ឈ្មោះវត្ថុ មនុស្ស និងសកម្មភាព កូនអាចចាប់ផ្តើមយល់សំណើសាមញ្ញរបស់អ្នក។ សូមចាប់ផ្តើមជាមួយសំណើខ្លីមួយ។ សង្កត់សម្លេងលើពាក្យដែលកុមារដឹងហើយ និងប្រើកាយវិការដើម្បីធ្វើឱ្យសារច្បាស់លាស់។ ធ្វើយ៉ាងណាទុកពេលគ្រប់គ្រាន់ឱ្យកូនឆ្លើយតបវិញ។ ធ្វើសំណើនោះឡើងវិញ បើចាំបាច់។

មុនដំបូងធ្វើសំណើអំពីវត្ថុ ឬមនុស្សដែលក្មេងឃើញជុំវិញខ្លួន។




បន្ទាប់មកធ្វើសំណើអំពីវត្ថុ ឬមនុស្សដែលក្មេងមិនឃើញ។




## ▶ របៀបលើកទឹកចិត្តឱ្យកូនរៀនពាក្យថែមទៀត

វិធីល្អបំផុតដើម្បីជួយកូនរៀនពាក្យថែមទៀត អ្នកត្រូវប្រាស្រ័យទាក់ទងជាមួយកូនឱ្យញឹកញាប់តាមដែលអាចធ្វើបាន និងលើកទឹកចិត្តកូនឱ្យនិយាយរកអ្នកវិញ។ នេះជាគំនិតខ្លះៗ សំរាប់ប្រាស្រ័យទាក់ទងជាមួយកូនឱ្យញឹកញាប់នៅរៀងរាល់ពេលថ្ងៃ :-

- សកម្មភាពប្រចាំថ្ងៃគឺជាពេលដ៏ល្អសំរាប់រៀនពាក្យនិយាយថ្មីៗ។ ប្រការនេះ ផ្តល់ឱកាសឱ្យកុមារហាត់ពាក្យដូចគ្នាម្តងហើយម្តងទៀត។



- សូមធ្វើជានិយាយខុស ដើម្បីលើក ទឹកចិត្តកុមារឱ្យកែតម្រូវអ្នក។




- ទុកចន្លោះពាក្យឱ្យកូនបំពេញក្នុងចម្រៀង ឬកំណាព្យសំរាប់ក្មេងតូចៗ ដែលកូនធ្លាប់ឮញឹកញាប់។ លើកទឹកចិត្តកូនឱ្យនិយាយបំពេញចន្លោះដែលគ្មានពាក្យ។




ក្រោយពេលចេះប្រើពាក្យទោល កុមារចាប់ផ្តើមផ្គុំពាក្យចូលគ្នាដើម្បីសំដែងគំនិតពេញលេញ។ ដំបូងកុមារផ្គុំពាក្យពីរម៉ាត់។ បន្ទាប់មកកុមារផ្គុំពាក្យបីម៉ាត់ និងទីបំផុតកុមារផ្គុំក្រុមពាក្យធំៗជាងនោះ។

ការផ្គុំក្រុមពាក្យចូលគ្នា គឺជាជំហានដ៏ធំមួយសំរាប់កុមារ។ វាអនុញ្ញាតឱ្យកុមារនិយាយអំពីវត្ថុ និងមនុស្សជុំវិញខ្លួនបានច្រើនថែមទៀត។ ដំបូងកុមារត្រូវស្វែងយល់របៀបដែលមនុស្សធ្វើទង្វើនេះ មុនពេលកុមារចាប់ផ្តើមចេះធ្វើដោយខ្លួនឯង។

## ការយល់ក្រុមពាក្យដែលមនុស្សដទៃប្រើប្រាស់

### ▶ របៀបជួយកូនឱ្យចេះយល់ក្រុមពាក្យ

1. នៅពេលកូនរបស់អ្នកហៅឈ្មោះវត្ថុ ឬមនុស្ស ចូរពង្រីកពាក្យសម្ដីដែលកូននិយាយ ។




សង្កត់សម្លេងពាក្យដែលអ្នកចង់ឱ្យកូនចេះ និងអនុវត្តក្រុមនោះឡើងវិញឱ្យបានច្រើនដង ។

2. ចូរសរសើរកូន បើសិនជាកូនឆ្លើយតបតាមរបៀបយល់ន័យ ។ បើសិនជាកូនមិនឆ្លើយតប ចូរនិយាយសារឡើងវិញឱ្យបានច្រើនដង ។




3. ប្រើពាក្យទាំងនេះឱ្យបានច្រើនដង តាមដែលអាចធ្វើបាននៅរៀងរាល់ពេលថ្ងៃ ។ លើកទឹកចិត្តគ្រួសារទាំងមូលឱ្យប្រើពាក្យទាំងនេះផងដែរ ។




នៅក្នុងឧទាហរណ៍នេះ ឪពុកម្ដាយកំណត់រួមគ្នាយកឈ្មោះវត្ថុមួយ (ពងមាន់) ជាមួយពាក្យរៀបរាប់អំពីវា (មាន់) ។ ការប្រើក្រុមពាក្យនៅក្នុងប្រយោគមួយពេញលេញ អាចជួយកុមារផ្ដោតអារម្មណ៍ទៅលើពាក្យទាំងនោះ ។

ដើម្បីបង្រៀនកូនឱ្យចេះក្រុមពាក្យដទៃទៀត ចូរព្យាយាមផ្គុំឈ្មោះវត្ថុ ឬមនុស្សចូលជាមួយគ្នា :-

- ពាក្យមួយដែលបង្ហាញថា មនុស្ស ឬវត្ថុកំពុងធ្វើអ្វីមួយ ។




- ពាក្យមួយដែលបង្ហាញថាអ្វីមួយជារបស់នរណាម្នាក់ វត្ថុមួយ មានទីតាំងនៅឯណា ។







- ពាក្យមួយដែលបង្ហាញថា វត្ថុ ឬ មនុស្សនៅកន្លែងណាមួយ ។

- ពាក្យមួយដែលបង្ហាញថា នរណាម្នាក់ចង់ឱ្យអ្វីមួយកើតឡើងម្តងទៀត ។




- ពាក្យមួយដែលបង្ហាញថា អ្វីមួយបានបញ្ចប់ ឬអ្វីមួយមិនអាចធ្វើកើត ។



### ▶ របៀបជួយកូនឱ្យចេះធ្វើតាមសំណើពីរជំហាន

នៅពេលដែលកូនអ្នកយល់ពាក្យបានច្រើន ក្មេងអាចចាប់ផ្តើមធ្វើតាមសំណើពិបាកៗបានច្រើនថែមទៀត ។ អ្នកចាប់ផ្តើមដោយពង្រីកសំណើសាមញ្ញដែលកូនយល់ហើយឱ្យទៅជាសំណើដែលមានពីរជំហាន ។




បន្ទាប់មក ធ្វើឱ្យសំណើនោះកាន់តែពិបាកថែមទៀត ។




## ការរៀនប្រើក្រុមពាក្យ

ដើម្បីឱ្យកុមារចេះចាប់ផ្តើមប្រើក្រុមពាក្យបានដោយខ្លួនឯង កុមារត្រូវតែស្គាល់ពាក្យឱ្យបានច្រើន ធ្វើដូច្នេះក្មេងអាចផ្គុំពាក្យតាមវិធីខុសប្លែកគ្នា ។

### ▶ វិធីជួយកូនឱ្យចេះផ្គុំពាក្យចូលគ្នា

នៅពេលកូននិយាយពាក្យទោលមួយ ចូរលើកទឹកចិត្តឱ្យកូនពង្រីកពាក្យអ្វីៗដែលកូនបាននិយាយ ។ អ្នកអាច :-

- ពង្រីកពាក្យដោយខ្លួនឯង និងលើកទឹកចិត្តកូនឱ្យធ្វើត្រាប់តាមអ្នក ។




- សួរសំណួរទៅកូន និងលើកទឹកចិត្តកូនឱ្យចេះឆ្លើយតបវិញ ។



នេះគឺជាគំនិតមួយចំនួនសំរាប់លើកទឹកចិត្តកុមារឱ្យប្រើក្រុមពាក្យ :-

- ចូរសួរកូនអំពីអ្វីដែលកូនកំពុងធ្វើ ។




- នៅពេលកុមារមានបញ្ហា ឱ្យកុមារប្រាប់អ្នក ថាត្រូវដោះស្រាយវាបែបណា ។




- ប្រើកូនឱ្យនាំព័ត៌មានងាយៗទៅឱ្យអ្នកណាម្នាក់ ។




- ចូរព្យាយាមនិទានរឿងជាមួយគ្នា ។ នៅពេលកូនបានឮ និងឃើញអ្នកនិទានរឿងនោះជាច្រើនលើក កូននឹងមានលទ្ធភាពនិទានរឿងនោះ បានមួយចំណែកដោយខ្លួនឯង ។



- លើកទឹកចិត្តកូនឱ្យចេះសំដែងតួអង្គមនុស្សខុសៗពីគ្នា។




- ពេលកុមារផ្គុំពាក្យចូលគ្នា ចូរសរសើរកុមារ។ ចូរប្រើឃ្លាពេញលេញដោយពង្រីកពាក្យអ្វីមួយដែលកុមារបាននិយាយ។ ប៉ុន្តែ កុំទាន់តម្រូវឱ្យកូនប្រើប្រយោគដែលពេញលេញ។




- ពេលលេងជាមួយគ្នា ចូរចែករំលែកគំនិត ឬអារម្មណ៍ដែលអ្នកកំពុងគិត។




ចូរបន្តអនុវត្តភាសានិយាយ។ ត្រូវចាំថា ជាការសំខាន់សំរាប់កូន ដើម្បីមានភាសាមួយដែលអ្នកទាំងអស់អាចប្រើប្រាស់រួមគ្នា។